ទីស្ដីការក្រសួងយុត្តិធម៌

លេខ ៣៣ រប.ចត-៩៤

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោកប្រធានតុលាការ អយ្យការខេត្ត ក្រុង**

**សូមជ្រាប ។**

**កម្មវត្ថុ:** អំពីក្របខ័ណ្ឌតុលាការ អយ្យការខេត្ត-ក្រុង

ខ្ញុំសូមជម្រាបលោកប្រធានតុលាការ អយ្យការខេត្ត ក្រុង ជ្រាបថាក្រសួងយុត្តិធម៌បានចេញសារាចរមួយ លេខ ៣៣៩ រប-៩៣ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៣ ដែលមានខ្លឹមសារដូចតទៅគឺ ការទទួលយក ឬការផ្លាស់ប្ដូរបុគ្គលិក ក្នុងអង្គភាពតុលាការ អយ្យការ ខេត្ត ក្រុង មិនអាចប្រព្រឹត្តទៅបានទេ បើគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ក្រោយពីសារាចរនេះចេញហើយ ក្រសួងយុត្តិធម៌បានពិនិត្យឃើញថា ស្ថិតិក្របខ័ណ្ឌតុលាការ អយ្យការខេត្ត ក្រុងមួយចំនួនមានការប្រែប្រួលជាបន្តបន្ទាប់ដោយគ្មានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមុន - ដែលជាហេតុធ្វើ អោយមានផលលំបាកដល់ប្រព័ន្ធចាត់តាំងក៏ដូចជាការធ្វើគំរោងថវិកាសំរាប់ឆ្នាំនេះ ។ ដើម្បីរក្សាស្ថេរភាពក្នុងពេលដែលក្រសួងយុត្តិធម៌ កំពុងតែរៀបចំប្រព័ន្ធក្របខ័ណ្ឌតុលាការ អយ្យការ ខេត្ត ក្រុង អោយបានល្អប្រសើរឡើងវិញនេះ ខ្ញុំសូមជម្រាបលោកប្រធានតុលាការ អយ្យការអមតុលាការខេត្ត ក្រុង ក្រសួងយុត្តិធម៌មិនទទួលខុសត្រូវចំពោះក្របខ័ណ្ឌណាដែលផ្ទុយពីស្ថិតិមានកំណត់ក្នុងតារាងបៀវត្សកន្លងរួចហើយនោះទេ ការផ្លាស់ប្ដូរការទទួលយកក្របខ័ណ្ឌណាដែលគ្មានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមុននោះក្រសួងយុត្តិធម៌មិនទទួលខុសត្រូវឡើយ។

អាស្រ័យហេតុនេះ បើមានករណីដែលទាក់ទងអំពីបញ្ហាក្របខ័ណ្ឌនេះ សូមលោកប្រធានពិនិត្យ និងអនុវត្តអោយបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងយុត្តិធម៌ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ១៩៩៤

រដ្ឋមន្ត្រី

**ចែម ស្ងួន**

ចម្លងជូន

- គណៈរដ្ឋមន្ត្រី
- ក្រសួងហិរញ្ញវត្ថុ
- អភិបាលខេត្ត ក្រុង
- ដើម្បីជ្រាបជាព័ត៌មាន